# ខ្មែរប៉ុស្តិ៍ ស.រ.អា

# KhmerPost USA

Printing The Cambodian World News

VOL. 06 ISSUE 100 Feb. 10th - .23th, 2012

សុបិន : (267) 253-3947, សែម : (781) 244-0522

MASSACHUSETTS
217 APPLETON ST.
LOWELL, MA 01852
PENNSYLVANIA
438 LINDLEY AVE.
PHILADELPHIA, PA 19120
RHODE ISLAND
NEW JERSEY


មាតិការឿង ទំព័រ


១-សម្ភាសន៍ជាមួយ សេរេណា ដួប គ្រូពេទ្យធ្មេញ....................០៣
២-អាម្ភកថា គំរប់លេខទី១០០ នៃការចេញផ្សាយ....................០៤
៣-គាត់ធ្វើកិច្ចការមនុស្សប្រុសតើមានអីធំដុំ?....................០៤
៤-សមាគមគាំទ្រស្រ្តីសារខ្មែរ....................១០
៥-The Cambodia Daily....................០៦ &១៣
៦-ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋបាលសម័យ....................១៦




## វិចារណកថា

# ខ្មែរប៉ុស្តិ៍លេខ១០០

ដោយ : ពិន សំខុន



●●●ផ្ដើមចេញផ្សាយពីលេខ១ នាថ្ងៃទី០១តុលា ឆ្នាំ២០០៧រហូតមក ដល់ថ្ងៃទី១០ កុម្ភៈ ២០១២នេះ យើងបានចែកផ្សាយសារព័ត៌ មានជាភាសាខ្មែរ នៅស.រ.អាឆ្នេរ ខាងកើតនេះ ចំនួន ១០០លេខហើយ ។ គឺជាការផ្សាយ យ៉ាងទៀងទាត់ ពីរលេខក្នុង១ខែ ផ្ដើមចែកផ្សាយពី៤០០០ ច្បាប់ក្នុង១ខែ រហូតមកដល់ពេលនេះ ពី១.៥ម៉ឺន ទៅ២ម៉ឺនច្បាប់ក្នុង១ខែ ។ យើងផ្ដើមផ្សាយនៅហ្វីឡាដែលហ្វៀ និងកាលីហ្វ័រនៀនាឆ្នាំដំបូង នៅឆ្នាំបន្ទបន្ទាប់ យើងផ្ដាច់ការគ្រប់គ្រងពី កាលីហ្វ័រនៀ មកពង្រីកតំបន់ផ្សព្វផ្សាយ តែឆ្នេរខាងកើតប៉ុណ្ណោះ ។ យើងចែកផ្សាយនៅរដ្ឋផែនស៊ុវេនា រដ្ឋញូជ័រហ្សេ រដ្ឋរ៉ូដអាយឡិន និងរដ្ឋម៉ាសាឈូសែត ។ តទៅទំព័រទី ០៨

# ស្វាគមន៍ សមាគមខ្មែរនៅឡូវែល

ដោយ : ខ្មែរប៉ុស្តិ៍ស.រ.អា

●សមាគមខ្មែរនៅឡូវែល នេះ មានការផ្លាស់ប្ដូរច្រើន នា ១០ឆ្នាំចុងក្រោយនេះ ។ ហៅជាអក្សរកាត់ជាភាសាអង់គ្លេសថា Cambodian Mutual Assistance Association (CMAA) សមាគមនេះមានអាយុ២៨ឆ្នាំហើយ ។ ពីដើមជាម្ចាស់នៃអាគារធំទូលាយមួយតែចាស់ណាស់ទៅហើយ ឥឡូវមកជួលបានអាគារតូចច្រឡឹងមួយនៅកណ្ដាលប្រជុំពាណិជ្ជកម្មខ្មែរថ្មី ជាងមុនមានការងាយស្រួលក្នុងការគ្រប់គ្រងច្រើន ។




ប្រធានសមាគមថ្មីគឺលោក Kevin Coughlin បានមើលឃើញអនាគតនៃសមាគមខ្មែរនេះ ប្រកបដោយក្តីសង្ឃឹម និងមោទនភាពគឺលោក ជាជនអាមេរិកាំង តទៅទំព័រទី២


300+ Cars a week

INTERSTATE Auctioncar.net
Auto Auction (603) 893-7777

$6,800 2003 Acurs MDX



Public Car Auction Open to All
ការដេញថ្លៃលក់ឡានជាសាធារណៈ

300+ Cars for Wholesale Prices
This Coming Wednesday and Saturday
Look Inside for Car Price, Auction Dates & information about How the Auction Works

៣០០ឡានសំរាប់តម្លៃដើម ការដេញនឹងមកដល់នៅថ្ងៃពុធ និងថ្ងៃសៅរ៍ អាចមើលតម្លៃក្នុងឡាន មើលកាលបរិច្ឆេទនៃការដេញថ្លៃ និងព័ត៌មានអំពីរបៀបដេញថ្លៃ

20 minutes from Lowell, MA
នៅ២០នាទីពីឡូវែល
just over 1hour from providence and Revere, MA
នៅជាង១ម៉ោង ពីប្រាវីដិន និង រីវើ ម៉ាស្សាឈូសេត
www.interstateautoauction.com



GENERAL DENTISTRY

ហួ ឌួង ពេទ្យធ្មេញសម្រាប់គ្រួសារ

466 Merrimack Street. Lowell, MA 01854
( Near City Hall ) / 978-441-1005

HOA DUONG, D.M.D., P.C.
GENERAL DENTISTRY

គ្រូពេទ្យជំនាញនិងមានបទពិសោធន៍
ច្រើនឆ្នាំក្នុងការពិនិត្យ
ថែរក្សា និងព្យាបាលជម្ងឺធ្មេញទូទៅ





Open: Monday, Tuesday, Wednesday, and Friday
from 10 a.m. – 6 p.m.
Saturday: from 10 a.m. – 4 p.m.
Closed: Thursday & Sunday
We accept all dental insurance & Medicaid

យើងទទួលយកគ្រប់ក្រុមហ៊ុនធានារ៉ាប់រង
សុខភាព និងការធានារ៉ាប់រងសុខភាពមនុស្សចាស់
យើងបើកទ្វារទទួលភ្ញៀវ ៥ថ្ងៃ ក្នុងមួយសប្តាហ៍
បិទទ្វារ : ថ្ងៃព្រហស្បតិ៍ និងថ្ងៃ អាទិត្យ
ទូរស័ព្ទដើម្បីណាត់ជួប (978) 441-1005
ម៉ោងធ្វើការពីម៉ោង 10ព្រឹក ដល់ 6ល្ងាច
ថ្ងៃសៅរ៍ ពីម៉ោង 10ព្រឹក ដល់ 4រសៀល
យើងមានបុគ្គលិកនិយាយភាសាខ្មែរ

978-441-1005

តមកទំព័រទី ១

# ស្វាគមន៍សមាគមខ្មែរ

ស្បែកសដែលបានទទួលការគាំទ្រយ៉ាងកក់ក្តៅ និង គ្រប់គ្រាន់ពីមនុស្សសំខាន់ៗនៃសហគមន៍ខ្មែរ -ហើយ មានសង្ឃឹមដោយលោកសម្លឹងឃើញថា នាយកប្រតិបត្តិនៃសមាគមខ្មែរ និងបុគ្គលិកជាមនុស្ស



Kevin Coughlin, CMAA President

*"This new calendar year brings great promise", said Kevin Coughlin, Lowell's new CMAA Board President. "Our many activities and strong goals will bring much respect to the Khmer community", he said, "We look forward to joining all our friend in our progress".*

សាច់ការមានជំនាញហើយជាមនុស្សបំរើសហគមន៍ ។ លោកបាននិយាយថា "ការងារដែលរាយពេញ១ឆ្នាំនៅក្នុងប្រកដិទិន គឺនាំមកនូវកិច្ចសន្យាយ៉ាងអស្ចារ្យ -សកម្មភាព និងវត្ថុបំណងដ៏រឹងមាំនឹងនាំឱ្យមានការគោរពដ៏ធំធេងដល់សហគមន៍ខ្មែរ" លោកប្រធានសមាគមបន្តទៀតថា "យើងស្វែងរកនូវការចូលរួមរបស់មិត្តភ័ក្រ្តយើងទាំងអស់នៅក្នុងដំណើរជឿនលឿនរបស់យើង" ។ ចំណែកឯនាយកប្រតិបត្តិថ្មី គឺលោក រ៉ាស៊ី រ៉ស អាន បានបន្តថា "គឺជាឆ្នាំថ្មីដ៏គួរឱ្យរំភើបសម្រាប់សមាគមខ្មែរ -គណកម្មាធិការនាយកយើងបានខិតខំរៀបគម្រោងយុទ្ធសាស្ត្រថ្មីដោយរាប់បញ្ចូលក្រុមប្រឹក្សានៃមនុស្សចាស់ ហើយឱ្យយោបល់ដល់អនាគតនៃសមាគមខ្មែរ" លោកបន្តថា "យើងស្វែងរកធ្វើការជាមួយសហគមន៍ឱ្យបានជិតស្និទ ហើយនឹងប្រកាសជោគជ័យជាមួយគ្នា" ។

សមាគមខ្មែរមានសភាពស្ងប់ស្ងាត់ ហើយស្វែងរកការរីកចំរើននាពេលនេះ ក៏ព្រោះតែសមាគមនេះ បានរងវិបត្តិដ៏ធ្ងន់ធ្ងរកាលពី១០ឆ្នាំមុន នាចុងអាណត្តិរបស់លោក សំខាន់ ឃឿន នាយកប្រតិបត្តិធំ រងវិបត្តិផ្ទៃក្នុងរួមគ្នានឹងវិបត្តិនៃប្រទេសការងារដែលកំពុងរីកស្គុះស្គាយជាមួយនឹងថវិកាសំរាប់កម្មវិធីនានាមានប្រមាណបីលានបានធ្លាក់មកទាបនៅប្រមាណជា៣០ម៉ឺនប៉ុណ្ណោះ ។ លោក វង់ រ៉ស បានត្រូវជ្រើសតាំងជានាយកប្រតិបត្តិដោះស្រាយវិបត្តិ



Rasy An, CMAA Executive Director

*"It is an exciting New Year for the CMAA", said Rasy An's Executive Director. "Our Board of Directors are working hard on a new strategic plan to include our Khmer Elders perspective and advise on the future of the CMAA", he said, "We are looking forward to work closely with our community and celebrate our success together".*



Vong Ros, Former CMAA Excutive Director

ឱ្យសមាគមជាបន្ត ។ "គ្មានជម្រើសណាល្អជាងត្រូវលក់អាគារដ៏ធំស្កឹមស្កៃតែមិនសូវមានប្រយោជន៍នោះទេ" នេះជាយោបល់លោក វង់ រ៉ស ជាមនុស្សសេដ្ឋកិច្ចអាគារចាស់បានត្រូវរៀបចំលក់ -៦ឆ្នាំក្រោយមកទើបលក់ដាច់ក្នុងតម្លៃ៨០ម៉ឺនដុល្លា រីឯដីធំទូលាយធ្វើឱ្យមានប្រាក់ចំណូលដល់សមាគម ៤ម៉ឺនក្នុងមួយឆ្នាំ ក្នុងរយៈពេល៣០ឆ្នាំទៅមុខដែលទាំងនេះបានក្លាយទៅជាសម្បត្តិសមាគមខ្មែរ ដែលត្រូវរៀបចំគ្រប់គ្រងដោយនយោបាយចំណាយតិចតួច រីឯកម្មវិធីដ៏ច្រើនត្រូវរៀបចំទៅជារបៀបពាណិជ្ជកម្ម ដែលតម្រូវឱ្យសមាគមរកប្រាក់ចំណូលពីកម្មវិធីរបស់ខ្លួន ។ ដោយវិធីនេះការគ្រប់គ្រងសមាគមហាក់មានលំនឹងឡើងវិញហើយ តែវិបត្តិនៃអតីតកាលនៅតែលងសមាគមនាអាណត្តិថ្មីនេះនៅឡើយដែលបន្ថយការចូលរួមមនុស្សសហគមន៍ ។

សមាគមខ្មែរនៅមានអំណោយផលច្រើនយ៉ាងនៅឡើយដោយសារសហគមន៍ខ្មែរនៅត្រូវការជំនួយពីសមាគមជាចាំបាច់នៅឡើយ -ក្រុងខ្មែរកំពុងនាំមកនូវសកម្មភាពសហគមន៍រួមគ្នា ដើម្បីទាញផលចំណេញពីឈ្មោះពិសេសនោះ -ហើយបុណ្យអុំទូកខ្មែរដែលនាំទស្សនិកជន និងអ្នកដំណើរ៣-៤ម៉ឺននាក់មកទីក្រុង គឺជាមោទនភាពនៃបុណ្យដែលមានកំណើតជាខ្មែរតែមួយប៉ុណ្ណោះ ។

ដូច្នេះ បើសមាគមខ្មែរចេះបំរើសហគមន៍ដោយភាពទន់ភ្លន់ និងដោយសុច្ចរិតនៃពូជខ្មែរដែលធ្លាប់រុងរឿងសហគមន៍គួរផ្តល់នូវការទុកចិត្តសាជាថ្មីឡើងវិញ រៀបគម្រោងរួមគ្នា ហើយទាំងអស់គ្នាប្រាកដជាធ្វើបុណ្យនៃជ័យជំនះរួមដោយជៀសមិនរួច ៕


OPEN HOUSE!
February 15, 2012
5:30-7:00 PM
សូមអញ្ជើញ

NOW ACCEPTING APPLICATIONS

2012-2013 GRADES K-6



**Lowell Community Charter Public School offers:**

- **Extended school day and year**
- **ពេលរៀនវែង ក្នុងរយៈពេលថ្ងៃ និងឆ្នាំ**
- **No Tuition – *We are a public school!***
- **រៀនដោយឥតគិតថ្លៃ – យើងជាសាលារៀនរដ្ឋ**
- **Gifted & Talented Students Program**
- **កម្មវិធីសិស្សរៀនពូកែ**
- **Before and After School Program**
- **កម្មវិធីមុន និងក្រោយពេលសិក្សា**

***LCCPS students achieved some of the highest growth scores on 2011 MCAS tests in the Merrimack Valley.***

**សិស្សសាលារៀនឆាទ័រទទួលបានលទ្ធផលពិន្ទុខ្ពស់បំផុតក្នុងការប្រឡងអឹមខាសឆ្នាំ២០១១ ម៉ីរីម៉ាក វាល្លី។**

**Contact Deborah Ye Motew**
**(978) 323-0800**
**dmotew@lccps.org**

LCCPS
LOWELL COMMUNITY CHARTER PUBLIC SCHOOL

206 Jackson Street. Lowell, MA 01852. Phone (978) 323-0800. www.lccps.org

ទំព័រ សុខភាព

# សម្ភាសន៍ជាមួយ សេរេណា ជួប គ្រូពេទ្យធ្មេញនៅឡូវែល

**ដោយ : ពិន សំខុន**

នៅចំពីមុខផ្លូវធំនៃទីក្រុងឡូវែល ផ្លាកសញ្ញានៃមន្ទីរថែ និងព្យាបាលធ្មេញដ៏ធំមួយ នៅមជ្ឈមណ្ឌល "ត្រេតវេយ" បានទាក់ទាញភ្នែកសាធារណជនឱ្យឃើញទីតាំងដ៏ទូលាយ ទំនើបស្អាត ។ ម្ចាស់នៃមន្ទីរពេទ្យធ្មេញនេះ ជាខ្មែរ បើកហាងជាឯកជន គឺវេជ្ជបណ្ឌិតខាងមាត់ និងធ្មេញ ឈ្មោះ លោកស្រី "សេរេណា ជួប" ដែលមានចំណេះ ជំនាញ និងមហិច្ឆិតាមិនចាញ់បរទេសឯទៀតឡើយ ។

ខ្មែរប៉ុស្តិ៍ស.រ.អា បានធ្វើបទសម្ភាសន៍មួយ នៅក្នុងមន្ទីរពេទ្យធ្មេញរបស់លោកស្រីកាលពីថ្ងៃទី២០ ខែធ្នូ ដែលមានអត្ថន័យដូចតទៅ:

**សេរេណា ជួប :** ខ្ញុំជាពេទ្យធ្មេញ general dentist ដែលទទួលមើលជម្ងឺក្នុងមាត់ទាំងមូល -យើងបិទធ្មេញប្រហោង -ដកធ្មេញ -ដកសរសៃធ្មេញ - ស្រោបធ្មេញ និងមានដាក់ធ្មេញមួយផ្នែក ឬមួយមាត់ក៏បាន -ខ្លះចង់បានធ្មេញស យើងសំអាតឱ្យសបាន យើងទទួលមើលទាំងចាស់ ទាំងជំទង់ ទាំងក្មេង ជាទូទៅយើងមើលទាំងអស់មានពេលខ្លះករណីលំបាកក៏យើងមានបញ្ជូនអ្នកជម្ងឺខ្លះទៅឱ្យអ្នកឯកទេសជំនាញដែរ...។



អ្នកស្រីទន្តពេទ្យ សេរេណា ជួប

**ខ្មែរប៉ុស្តិ៍ស.រ.អា :** ខ្ញុំឃើញក្នុងបន្ទប់ព្យាបាលហាក់ដូចជា មានឧបករណ៍ ឥតខ្វះអ្វីទេ តើអ្វីខ្លះទៅដែលនៅខ្វះត្រូវការអ្នកឯកទេសជំនាញនោះ... តើប្រដាប់ថតឆ្អឹងឬសធ្មេញនោះឬ?

**សេរេណា ជួប :** ទេៗអាហ្នឹងខ្ញុំមាន Digital X Ray ខ្ញុំទិញមកដាក់ថ្មីថែសកាលពី៩ខែមុន ហើយទំនើប ថតលឿនទៀតផង។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** ជាទូទៅ ភ្ញៀវដែលបានឃើញកន្លែងព្យាបាលស្អាតរបៀបនេះ តែនាំគ្នាមកទៀត... តើភ្ញៀវណាខ្លះទៅដែលច្រើនមកព្យាបាលទីនេះ?

**សេរេណា ជួប :** មានមកស្ទើរគ្រប់សាសន៍នៅទីនេះ តែច្រើនជាងគេគឺខ្មែរ ខ្មែរមកច្រើន -ព្រោះគេដឹងថាខ្ញុំជាខ្មែរ អ្នកជំនួយការខ្ញុំក៏ខ្មែរ ខ្ញុំមានមោទនភាពណាស់ ដោយឃើញបង ប្អូនខ្មែរមកច្រើន ដោយពួកគាត់ដឹងថា យើងខ្ញុំនឹងមើលថែទាំពួកគាត់ ឱ្យបានប្រសើរបំផុត -លើសពីនេះទៅទៀត ពួកគាត់មានការងាយ ស្រួលនឹងសួរ ឬនឹងតវ៉ាហើយក៏យល់ពីចម្លើយវិញដែរ ដូចជាព្រឹកមិញ នេះ លោកពូម្នាក់នោះគាត់ថា "មិនហ៊ានទៅកន្លែងពួក "អាតាំង" ទេ ពីព្រោះខ្លាចគេសួរអីមក ឯងមិនដឹងថាត្រូវឆ្លើយយ៉ាងណា មោកន្លែងខ្មែរគ្នាឯង ស្រួលយល់គ្នាផង" តែយល់គ្នាធ្វើការបានការណ៍ល្អច្រើនជូន។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** តើពេទ្យធ្មេញដូចគ្នានេះ មានច្រើនទេនៅទីក្រុងឡូវែលនេះ?

**សេរេណា ជួប :** មានច្រើនណាស់ ប្រហែលជា៣០កន្លែងឯណោះ តែកន្លែងព្យាបាលធ្មេញជាខ្មែរមានតែពីរទេ គឺខ្ញុំហ្នឹងមួយ ហើយលោកអ៊ុំ កែវ សម្បត្តិ នោះមួយទៀត។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** មន្ទីរពេទ្យធ្មេញនេះ ហាក់ដូចជាទូលំទូលាយច្រើន បើប្រៀបធៀបទៅពេទ្យធ្មេញឯទៀតៗ!

**សេរេណា ជួប :** មែន វាធំបន្តិចមែនសម្រាប់រូបខ្ញុំនៅពេលនេះ! តែខ្ញុំគិតថា បើការងារចេះតែកើនឡើងនៅ១០ឆ្នាំទៅមុខទៀត ខ្ញុំមិនចាំបាច់ប្តូរទីទៅតាំងនៅកន្លែងផ្សេងណាទេ កន្លែងនេះក៏នឹងអាចទទួលភ្ញៀវច្រើនឡើងបានដែរ។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** នៅក្មេង ប្រកបមុខរបរមានជំនាញ មានទីតាំងយ៉ាងពេញមុខ គឺប្រាកដជារាប់ជាជោគជ័យក្នុងជីវិតបានហើយ តើអ្វីទៅដែលនាំឱ្យលោកស្រី ទៅចាប់មុខរបរជាពេទ្យធ្មេញនោះ?

**សេរេណា ជួប :** ម្តាយខ្ញុំជាឆ្មប ឪពុកខ្ញុំជាវិស្វករ ដល់ខ្ញុំធំឡើងខ្ញុំចង់រើសយកមុខវិជ្ជាខាងពេទ្យ តែបើមិនដូច្នោះទេ ខ្ញុំនឹងយកខាងវិស្វកម្ម -ខ្ញុំបានទៅធ្វើការស្ម័គ្រចិត្តច្រើនកន្លែង ហើយច្រើនតែមន្ទីរពេទ្យដល់ខ្ញុំទៅសាកលវិទ្យាល័យ ខ្ញុំក៏ជ្រើសខាងពេទ្យទៅ -រីឯការជ្រើសយកជាពេទ្យធ្មេញ គឺខ្ញុំមានអ្នកណែនាំ (Mentor) ជាពេទ្យធ្មេញខាងវះកាត់ ធ្វើឱ្យខ្ញុំបានស្គាល់មុខវិជ្ជានោះ ខ្ញុំក៏យកឯកទេសខាងពេទ្យធ្មេញនោះទៅ។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** ចុះលោកស្រីមានបទពិសោធន៍ប៉ុណ្ណា ទើបហ៊ានបើកមុខរបរនេះដោយខ្លួនឯង?

**សេរេណា ជួប :** ខ្ញុំប្រលងជាប់ឆ្នាំ២០០០ ខ្ញុំធ្វើការ ឱ្យពេទ្យធ្មេញនានាច្រើនកន្លែងអស់១២ឆ្នាំ មុននឹងខ្ញុំបើកមន្ទីរពេទ្យនេះ កាលពីឆ្នាំមុនដោយខ្លួនឯង។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** ចុះហេតុអ្វីបានជាមកធ្វើជាពេទ្យធ្មេញនៅឡូវែល?

**សេរេណា ជួប :** ខ្ញុំធំឡើងនៅឡូវែលនេះ ខ្ញុំចេញទៅរៀននៅរដ្ឋផ្សេងៗ មែនអស់ច្រើនឆ្នាំរៀនចប់ ខ្ញុំត្រឡប់មកភូមិកំណើតខ្ញុំវិញ ពីព្រោះម្តាយខ្ញុំនៅទីនេះ ធ្វើការនៅឡូវែលចំនួន២០ឆ្នាំបំរើសហគមន៍ ឯខ្ញុំមានមោទនភាពនឹងត្រឡប់មកបំពេញតួនាទីខ្ញុំនៅឡូវែលវិញ ព្រោះខ្ញុំដឹងច្បាស់ថាខ្ញុំមានឬសគល់នៅទីនេះប្រាកដ ជាអាចជួយអ្វីខ្លះដល់សហគមន៍បាន។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** ការងារលោកស្រី ជាមុខរបរពាណិជ្ជកម្ម !

**សេរេណា ជួប :** មែន! ជាមុខរបរ **តទៅទំព័រទី០៧**




វេជ្ជបណ្ឌិត យ័ន ម៉ាយរ៉ូ គ្រូពេទ្យជំនាញអាចជួយលោកអ្នកឲ្យស្រួលខ្លួនឡើងវិញ ហើយនៅស្រួលខ្លួនរហូតបាន



Yuan Mirow, MD
*Internal Medicine*

**មន្ទីរពេទ្យអាញស្តាញ មានសេចក្តីរីករាយ នឹងជូនដំណឹងថា វេជ្ជបណ្ឌិត ម៉ាយរ៉ូ ឥឡូវនេះទទួលព្យាបាលអ្នកជម្ងឺថ្មីហើយ**

មានសញ្ញាប័ត្រមកពីសាលាពេទ្យនៅ យូណាន វេជ្ជបណ្ឌិត ម៉ាយរ៉ូ បានបំពេញការសិក្សានៅក្នុងមន្ទីរពេទ្យ "អេពីស្កូពុល" ហ្វីឡាដែលហ្វៀ នាងនិយាយភាសាចិន ម៉ង់ឌ្រីន និង ខនតុង មុខជំនាញរបស់នាងគឺថែទាំសម្រាប់ការពារក្នុងករណី:

- ជម្ងឺហឺត
- ឈឺសរសៃរបេះដូង
- ការចិញ្ចឹមខ្លួន/ជំងឺធាត់
- ទឹកនោមផ្អែម
- អ្វីដែលទាក់ទងសុខភាពស្ត្រី

វេជ្ជបណ្ឌិត ម៉ាយរ៉ូ គឺជាផ្នែកមួយនៃប្រព័ន្ធទាក់ទងថែសុខភាពរបស់ពេទ្យអាញ ស្តាយ ដែលមានឈ្មោះល្បី ថាបានព្យាបាលយ៉ាងល្អបំផុត ចំនួន១៤០ឆ្នាំមកហើយ ។ អាញស្តាញ ទទួលបានចំណាត់ថ្នាក់ទី២៥នៃការស្ទាបស្ទង់មតិទស្សនាវដ្តីនៃវេជ្ជបណ្ឌិតកំពូលឆ្នាំ២០១១ ហើយជាមន្ទីរពេទ្យតែមួយដែលប្រព័ន្ធសុខភាពបានឈ្នះការកោតសរសើរដំបូងគេ អំពីគុណភាព ។
ចង់ជួបវេជ្ជបណ្ឌិត ម៉ាយរ៉ូ សូមទូរស័ព្ទទៅ 215-248-0112

1-800-EINSTEIN | www.einstein.edu

Einstein Physicians

©2011 EHN PCN-2429-11

# East Coast Center

**for Plastic & Laser Surgery**

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com


Skin Care Products


Tummy Tuck


Breast Lift


Beast Enlargement


Nose Surgery


Eyelid Surgery


Face Lift


Dermabrasion

**ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន អាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឲ្យធំ កែខ្ទង់ច្រមុះ កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។ និងមានលក់ឧបករណ៏កែសម្ផស្សផ្សេងៗជាច្រើនទៀត**

381 West Broadway South Boston, MA 02127
**(617) 464 - 0001**

# ក្រុមហ៊ុនទេសចរណ៍ ភ្នំពេញអន្តរជាតិ

**Phnom Penh International Travel Services**

**21 Branch St., Ste #1**
**Lowell, MA 01851**
**Tell: 978-970-5999**
**Fax: 978-970-5599**

***109 Lafayette St. #C-5***
***New York, NY 10001***
***Tell: 212-219-2299***
***Fax: 212-219-9930***

- *លក់សំបុត្រយន្តហោះសម្រាប់ក្នុង និងក្រៅប្រទេស*
- *ធ្វើលិខិតធានា ប្ដី ប្រពន្ធ ឬគូដណ្ដឹងពីស្រុកខ្មែរ*
- *ធ្វើលិខិតសុំច្បាប់ចេញចូល -Re-Entry Permit*
- *ពន្យា Passport ខ្មែរ Laisser Passer*
- *ធ្វើទិដ្ឋាការ Visa ទៅអាស៊ី*
- *ធ្វើលិខិតសុំ Green Card I-94 Work Permit*
- *បំពេញសុំចូលសញ្ជាតិ*
- *ថតរូបសម្រាប់ចូលសញ្ជាតិ និងទទួលផ្ញើប្រាក់ទៅស្រុកខ្មែរគ្រប់ប្រទេស*
- *លក់ Money Order និងបោះត្រា Nortary Public*




***978-970-5999***

# GATEWAY FAMILY DENTAL

**NOW OPENED AT GATEWAY CENTER II (978) 455-5044**

**151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)**



**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.




**WE PROVIDE ALL SERVICES INCLUDING: យើងផ្ដល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វើរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

**MOST DENTAL INSURANCES ACCEPTED**
**INCLUDING MASSHEALTH FOR KIDS**
**FINANCING AVALIABLE**
**យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន**
**Masshealth for Kids**
**យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ**
**CALL FOR YOUR FREE CONSULTATION**
**(978) 455-5044**

www.gatewayfamilydental.com

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី១០ ខែកុម្ភៈ ឆ្នាំ២០១២

# រដ្ឋាភិបាលកម្ពុជាបានដេញថៃមិនឱ្យចូលមកកសាងវត្តអារាមនៅលើភ្នំទ្រព្យ

Zsombor Peter និង ផន បុប្ផា
**ខេមបូឌា ដេលី**

មន្ត្រីបានលើកឡើងកាលពីម្សិលមិញថា បន្ទាប់ពីបានធ្វើឱ្យមានការវិវឌ្ឍតិចតួចជាមួយប្រទេសថៃជុំវិញទឹកដីមានវិវាទជាប់ប្រាសាទព្រះវិហារនោះ ពេលនេះប្រទេសកម្ពុជាបានចោទប្រកាន់ប្រទេសជិតខាងរបស់ខ្លួនមួយនេះ ជាផ្លូវការហើយពីបទរំលោភបំពានដីកាបង្គាប់មួយចុះថ្ងៃ ទី១៨ ខែកក្កដា របស់តុលាការកំពូលរបស់អង្គការសហប្រជាជាតិតាមរយៈការព្យាយាមកសាងវត្តអារាមថ្មីមួយនៅខាងក្នុងតំបន់ដែលត្រូវបានស្នើឡើងមិនឱ្យមានកងទ័ព។

សេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិហៅកាត់ថា ICJ បានបង្គាប់ឱ្យទាហ៊ានថៃ និងទាហ៊ានកម្ពុជាដកចេញ "ជាបន្ទាន់" ពីតំបន់គ្មានយោធាថ្មីមួយនៅជុំវិញប្រាសាទនេះ និងជុំវិញទឹកដីមានវិវាទ ។ ទោះបីជាមិនទាន់មានភាគីណាមួយដកទ័ពចេញនៅឡើយក្តី លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីកម្ពុជាបានមានប្រសាសន៍កាលពីម្សិលមិញថា ប្រទេសថៃបានបំពានដីកាបង្គាប់នេះតាមរយៈការព្យាយាមកសាងវត្តអារាមថ្មីមួយនៅខាងក្នុងតំបន់មិនឱ្យមានកងទ័ពនេះ។

លោកបានមានប្រសាសន៍ថា "ក្នុងរយៈពេលពីរបីថ្ងៃចុងក្រោយនេះ ពួកគេបានព្យាយាមនាំគ្រឿងសំណង់ចូលមកដើម្បីកសាងវត្តអារាមមួយនៅលើភ្នំទ្រព្យ និងដើម្បីដាក់តម្កល់ព្រះពុទ្ធបដិមាមួយអង្គនៅខាងក្នុង ។ ប៉ុន្តែយើងបានឱ្យពួកគេចេញទៅវិញតាមរយៈការទូត"។

លោក ផៃ ស៊ីផាន បានមានប្រសាសន៍ថា សេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិបានហាមប្រាមភាគីថៃមិនឱ្យធ្វើសកម្មភាពអ្វីទាំងអស់នៅខាងក្នុងតំបន់គ្មានយោធានេះ ប៉ុន្តែលោកបានបង្វែររាល់សំនួរផ្សេងទៀតទៅលោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស។

លោក កុយ គួង បានបដិសេធមិនធ្វើអត្ថាធិប្បាយលម្អិតអំពីការរំលោភបំពាននេះទេ ប៉ុន្តែលោកបានអះអាងថា រដ្ឋាភិបាលបានដាក់កំណត់តវ៉ារបស់ខ្លួនទៅស្ថានទូតថៃប្រចាំប្រទេសកម្ពុជា និងទៅតុលាការយុត្តិធម៌អន្តរជាតិរួចហើយ។

លោកបានលើកឡើងនៅក្នុងអ៊ីមែលខ្លីមួយថា "ក្រសួងការបរទេសកម្ពុជាបានដាក់កំណត់តវ៉ាមួយទៅស្ថានទូតថៃប្រចាំរាជធានីភ្នំពេញ កាលពីថ្ងៃពុធហើយកំណត់តវ៉ានេះ ក៏ត្រូវបានចម្លងជូនទៅតុលាការយុត្តិធម៌អន្តរជាតិដែរ"។

លោកឧត្តមសេនីយ៍ឯក ស្រី ឌឹក មេបញ្ជាការកងពលធំអន្តរាគមន៍លេខ៣នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការនៃកងកម្លាំងការពារប្រាសាទព្រះវិហារបានអះអាងថា ថៃពិតជាបានប៉ុនប៉ងនាំគ្រឿងសំណង់និងព្រះពុទ្ធបដិមាមួយព្រះអង្គឡើងទៅលើភ្នំទ្រព្យប្រាកដមែន ប៉ុន្តែបានបង្វែររាល់សំណួរផ្សេងទៀតទៅលោកអភិបាលរងខេត្ត ស ថាវី ដែលមិនអាចទាក់ទងបាន។

គ្មានមន្ត្រីកម្ពុជារូបណាអាចបញ្ជាក់ឱ្យបានច្បាស់លាស់ថា តើខណាមួយនៃសេចក្តីសម្រេចចុះថ្ងៃទី១៨ ខែកក្កដា របស់តុលាការយុត្តិធម៌អន្តរជាតិដែលភាគីថៃបានរំលោភបំពាននោះទេ។

ក្រៅពីបង្គាប់ឱ្យកងទ័ពថៃ និងកងទ័ពកម្ពុជាដកចេញពីតំបន់គ្មានយោធាសេចក្តីសម្រេចនេះក៏អំពាវនាវឱ្យភាគីទាំងពីរ "កុំធ្វើសកម្មភាពណាមួយដែលអាចធ្វើឱ្យវិវាទនេះកាន់តែធ្ងន់ធ្ងរទៅៗ និងធ្វើឱ្យកាន់តែពិបាកដោះស្រាយឱ្យសោះ"៕

# ដាក់ពង្រាយទាហានដើម្បីបំបែកការតវ៉ាដីធ្លីនៅក្នុងខេត្តកំពង់ស្ពឺ

ឃី សុវុឌ្ឍី និង Lauren Crothers
ខេមបូឌា ដេលី

បុគ្គលិកសិទ្ធិមនុស្សបាននិយាយថា ទាហាននៃកងយោធពលខេមរភូមិន្ទ(RCAF)ប្រដាប់ដោយអាវុធគ្រប់ដៃជាង៤០នាក់ ត្រូវបានដាក់ពង្រាយកាលពីម្សិលមិញ ដើម្បីបញ្ឈប់ការតវ៉ាមួយធ្វើឡើងនៅខាងក្រៅសាលាដំបូងខេត្តកំពង់ស្ពឺ និងមានគំរាមបាញ់ប្រហារប្រសិនបើអ្នកតវ៉ាប្រមាណ២០០នាក់ មិនព្រមឈប់ធ្វើបាតុកម្មរបស់ខ្លួន ដើម្បីទាមទារឱ្យដោះលែងអ្នកភូមិដែលកំពុងជាប់ឃុំម្នាក់ទេ។

ទាហានប្រដាប់អាវុធធុនធ្ងន់ស្លៀកពាក់ឯកសណ្ឋានគ្មានឈ្មោះអង្គភាព ឬសញ្ញាសម្គាល់កងពលត្រូវបានដាក់ពង្រាយនៅវេលាម៉ោងប្រហែល១១ព្រឹក និងដើម្បីបំបែកក្រុមអ្នកតវ៉ានៅខាងក្រៅតុលាការ។

យោងតាមលោក ចាន់ សុវៀត ប្រធានផ្នែកសង្កេតការណ៍នៅអង្គការសិទ្ធិមនុស្សអាដហុកបានឱ្យដឹងថា អ្នកភូមិមកពីឃុំអមលាំងក្នុងស្រុកថ្ពង បានប្រមូលផ្តុំគ្នា ដើម្បីដាក់ញត្តិជូនតុលាការ ដោយទាមទារឱ្យលើកលែងការចោទប្រកាន់មកលើអ្នកភូមិឈ្មោះ ជុំ ស្រីនួន។

អ្នកស្រី ស្រីនួន ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១៥ ខែធ្នូ និងត្រូវបានចោទប្រកាន់ពីបទកាន់កាប់ដីដោយខុសច្បាប់ដែលជាកម្មសិទ្ធិរបស់ទាហានម្នាក់ឈ្មោះ ហ៊ឹម សំអឿន ។ ទោះជាយ៉ាងណាអ្នកស្រី ស្រីនួន ប្រកែកថាអ្នកស្រីបានរស់នៅលើដីនេះអស់រយៈពេល១០ឆ្នាំកន្លងមកហើយ ព្រមទាំងចោទថា ទាហានរូបនេះគ្មានដីទេ ប៉ុន្តែបានធ្វើប័ណ្ណកម្មសិទ្ធិមួយ ដើម្បីជួយពង្រីកចំការស្ករអំពៅមួយកន្លែងនៅក្នុងឃុំអមលាំង។

លោក សុវៀត បានថ្លែងថា ឆ្លើយតបទៅនឹងការតវ៉ាដោយសន្តិវិធីរបស់អ្នកភូមិនៅខាងក្រៅរបងតុលាការមេបញ្ជាការយោធា RCAF ម្នាក់បានមកដល់ និងទាហានពេញមួយឡានបានចេញមុខដាក់ឱសានវាទដល់ស្លាប់ដល់អ្នកភូមិណាដែលនៅតែព្យាយាមបើកច្រកចូលក្នុងបរិវេណតុលាការ។

លោក សុវៀត ដែលមានវត្តមាននៅតុលាការ និងបានឃើញហេតុការណ៍នោះបានថ្លែងថា "គាត់បានគំរាមប្រជាពលរដ្ឋឱ្យបិទច្រកវិញ ហើយប្រាប់ពួកគាត់ថាប្រសិនបើពួកគេមិនព្រមបិទទេ (ទាហាន)នឹងបាញ់ពួកគាត់"។

លោកបានថ្លែងថា មេបញ្ជាការដែលមិនប្រាប់ឈ្មោះរូបនេះ ក៏ព្រមានផងដែរ គាត់និងបញ្ជាឱ្យទាហានរបស់គាត់"ដែលហាក់ដូចជាពួកកំពុងតែត្រៀមប្រយុទ្ធនឹងសត្រូវ"ដើម្បីវាយក្បាលអ្នកភូមិនឹងស្វាយកាំភ្លើងប្រសិនបើពួកគាត់មិនព្រមធ្វើតាមទេនោះ។

លោក សុវៀត បានថ្លែងថា ប្រឈមនិងទាហានប្រដាប់ដោយអាវុធក្រុមអ្នកតវ៉ាធ្វើតាមការព្រមានហើយឈប់តវ៉ាទៀត ។ លោកបានបន្ថែមថា គ្មាននរណាម្នាក់រងរបួសក្នុងការប្រឈមមុខគ្នានោះឡើយហើយអ្នកភូមិក៏បរាជ័យក្នុងការដាក់ញត្តិរបស់ខ្លួនដែរ។

អ្នកស្រុកមកពីឃុំអមលាំង ជាអ្នកមានវិវាទដីធ្លីជាយូរមកហើយជាមួយក្រុមហ៊ុនផលិតស្ករសភ្នំពេញរបស់មហាសេដ្ឋី លី យ៉ុងផាត់ សមាជិកព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជា។

លោក វ័ត្ត ថាវី អ្នកសង្កេតការណ៍របស់អង្គការអាដហុកប្រចាំនៅខេត្តកំពង់ស្ពឺបានថ្លែងថា ទាហានទាំងនេះមកពីយោធភូមិភាគ៣របស់កងយោធពលខេមរភូមិន្ទ **តទៅទំព័រទី ០៧**

# Gov´t Objects to Thai Pagoda Push at Border

**By Zsombor Peter And Phorn Bopha**
THE CAMBODIA DAILY

After making modest progress with Thailand over the disputed border territory next to Preah Vihear temple, Cambodia has now officially accused its neighbor of breaching a July 18 order from the UN´s top court by trying to build a new pagoda inside the proposed demilitarized zone, officials said yesterday.

The International Court of Justice's (ICJ) ruling ordered Thai and Cambodian soldiers to "immediately" pull out of a new demilitarized zone around the temple and the disputed land. Though neither side has withdrawn, Council of Ministers spokesman Phay Siphan said yesterday that Thailand had breached the order by trying to build a new pagoda inside the proposed demilitarized zone.

"It was in the last two or three days, they tried to bring in constru- ction material to build a pagoda in Phnom Trop and to put a statue inside," he said. "But we managed to get them out by diplomatic means."

Mr. Siphan said the ICJ ruling barred Thailand from all activity inside the demilitarized zone, but referred all other questions to the Ministry of foreign Affairs spokes man Koy Kuong.

Mr. Kuong declined to comment on the specifics of the alleged breach, but confirmed that the government had lodged its complaint both with the Thai Embassy and the ICJ.

"The Cambodian Foreign Ministry sent a protest note to the Thai Embassy in Phnom Penh **Continue to page 10**

# Soldiers Deployed to Stamp Out Land Protest in Kompong Speu

**By Khy Sovuthy and Lauren Crothers**
THE CAMBODIA DAILY

More than 40 armed RCAF troops were deployed yesterday to stop a land dispute protest outside the Kompong Speu Provincial Court and threatened, according to human rights workers, to open fire if some 200 villagers did not stop their demonstration to gain the release of a jailed villager.

The heavily armed troops, whose uni- forms bore no identifiable unit or division insignia, were deployed at about 11 a.m. to disperse the protesters from outside the court.

The villagers from Thpong district´s Omlaing commune had gathered to sub- mit a petition to the court demanding that charges against villager Chum Srey Nuon, be dropped, according to for Soveth, deputy chief monitor for rights group Adhoc.

Ms. Srey Nuon was arrested on Dec. 15 and charged with illegally occupying land that belongs to a soldier named Hoem Sam Oeun.

However, Ms. Srey Nuon has argued that she had lived on the land for 10 years and that the soldier did not own the land, but had made the ownership claim as a means to help a sugar plantation expand to Omlaing commune.

In response to the villagers´ peaceful protest outside the court, an RCAF mili- tary commander arrived with a truck full of soldiers and issued a deadly ultimatum to the villagers who were trying to push open the gate to the court compound, Mr. Soveth said.

"He threatened the people to close the [gate] and told them that if they did not, they would be shot," said Mr. Soveth, who was at the court and witnessed the events.

The unidentified commander also warned that he would order his troops, " who looked like they were preparing to fight an enemy," to beat the villagers on the head with **Continue to page 13**

## តមកទំព័រទី ៦ ដាក់ពង្រាយទាហានដើម្បីបំបែកការតវ៉ាដីធ្លី...

ដែលមានមូលដ្ឋាននៅខេត្តកំពង់ស្ពឺនេះ។ ទោះជាយ៉ាងណាមេបញ្ជាការរងនៃ RCAF លោក គង់ ប៊ុនថន បានមានប្រសាសន៍ថា លោកមិនដឹងថា តើទាហានដែលមកដាក់ពង្រាយនោះ មកពីយោធភូមិភាគរបស់លោកទេ។

លោកបានមានប្រសាសន៍ថា "ខ្ញុំមិនដឹងអំពីរឿងនេះទេ"។

លោក ទូច ហ៊ាង ស្នងការនគរបាលខេត្តកំពង់ស្ពឺ និងលោក ខួត ពេជ្រ ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ បានបដិសេធមិនធ្វើអត្ថាធិប្បាយទេ។

លោក ផល វណ្ណៈ តំណាងភូមិបានមានប្រសាសន៍ថា ក្រុមអ្នកភូមិក៏កំពុងតែតវ៉ា ចំពោះការកោះអ្នកភូមិម្នាក់ទៀតឈ្មោះ ហាក់ ហាំងគីម ដែលតុលាការចង់សាកសួរជុំវិញការចោទប្រកាន់ថា គាត់បានប្រព្រឹត្តអំពើឆបោកក្នុងវិវាទដីធ្លីជាមួយក្រុមហ៊ុនចម្ការផលិតស្ករសភ្នំពេញរបស់លោក លី យ៉ុងផាត់ ។

លោកបានថ្លែងថា "តាំងពីឆ្នាំ២០១០មកមានអ្នកភូមិ៤៩នាក់ហើយដែលត្រូវបានសាលាដំបូងខេត្តកោះហៅមកសាកសួរ ដោយជាប់ពាក់ព័ន្ធនិងវិវាទដីធ្លីជាមួយក្រុមហ៊ុន លី យ៉ុងផាត់ "។ លោក បានថ្លែងថា "យើងមិនមែនជាសត្រូវទេ ដូច្នេះហេតុអ្វីបានជាទាហានយកអាវុធមកគំរាមយើង ? យើងចង់ឱ្យរដ្ឋាភិបាលដោះស្រាយរឿងនេះ"។

លោកស្រី ឈាង គីមស៊ុន តំណាងរបស់ក្រុមហ៊ុនផលិតស្ករសភ្នំពេញ បានបដិសេធចំពោះការពាក់ព័ន្ធជាមួយរឿងនេះ ។ អ្នកស្រីបានបន្ថែមថា "ក្រុមហ៊ុនរបស់ខ្ញុំមិនពាក់ព័ន្ធជាមួយអ្នកភូមិអមលាំងទាំងនោះទេ ។ ខ្ញុំគិតថា អ្នកភូមិទាំងនោះរស់នៅលើដីរបស់គេ ដូច្នេះ ពួកគេត្រូវបានបណ្ដេញចេញពីដីនោះ ។ វាជារឿងបុគ្គលទេ"។

លោក លី យ៉ុងផាត់ ជាអ្នកឧបត្ថម្ភផ្លូវការដល់កងវរសេនាតូចលេខ៣១៣របស់កងយោធពលខេមរភូមិន្ទតាមប្រព័ន្ធឧបត្ថម្ភបែបបក្ខពួក ដែលភ្ជាប់ក្រុមហ៊ុនឯកជននេះជាមួយនិងអង្គភាពយោធា ។ កាលពីក្នុងខែមីនា ឆ្នាំ២០១០ សមាជិកនៃកងសេនាតូចនេះ ត្រូវបានបញ្ជូនទៅបំបែកការតវ៉ារបស់អ្នកតវ៉ាមកពីឃុំអមលាំង។

តាមសេចក្ដីរាយការណ៍មួយចេញផ្សាយកាលពីខែមុន ដោយអង្គការសិទ្ធិមនុស្ស លីកាដូ បានពណ៌នាអំពីវិបត្តិចាប់យកដីថា ជាការប្រែក្លាយទៅជាអំពើហិង្សានៅក្នុងរយៈពេល២ខែចុងក្រោយនេះ ដោយហេតុការណ៍យ៉ាងតិចចំនួន៩ករណី មានជាប់ពាក់ព័ន្ធទៅនឹងកងកម្លាំងប្រដាប់អាវុធដែលបានបាញ់ប្រហារអ្នកតវ៉ា។ អ្នកស្រុកសរុប១៩នាក់បានរងរបួសនៅកន្លែងតវ៉ាមានទាំងការបាញ់ប្រហារ យ៉ាងហោចណាស់៧ករណីផងដែរ"។

កាលពីថ្ងៃទី៣១ខែមករា និងបន្ទាប់ពីសន្តិសុខឯកជន បានបាញ់ប្រហារទៅលើអ្នកភូមិ អំឡុងការតវ៉ាដីធ្លីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានព្រមានបណ្ដាក្រុមហ៊ុនអភិវឌ្ឍន៍ដីធ្លីមិនឱ្យប្រើអំពើហិង្សា ក្នុងវិវាទបែបនេះ បើមិនអ៊ីចឹងទេ សិទ្ធិគ្រប់សម្បទានដីរបស់គេអាចនិងត្រូវដកហូត ។

លោក លី យ៉ុងផាត់ អ្នកនាំពាក្យទីស្ដីការគណៈរដ្ឋមន្ត្រី បានមានប្រសាសន៍ថា លោកមិនបានដឹងអំពីការដាក់ពង្រាយយោធានៅខាងមុខសាលាដំបូងខេត្តកំពង់ស្ពឺនោះទេ ប៉ុន្តែលោកបានលើកឡើងម្ដងទៀត អំពីការព្រមានរបស់លោក ហ៊ុន សែន ។

លោក ស៊ីផាត បានមានប្រសាសន៍ថា "ខ្ញុំមិនបានដឹងរឿងក្ដីនេះនៅខេត្តកំពង់ស្ពឺទេ ប៉ុន្តែអ្នកដែលរំលោភបំពានទៅលើអ្វីដែលលោកនាយករដ្ឋមន្ត្រីបានថ្លែងនោះនឹងត្រូវផ្ដន្ទាទោស ។ សូម្បីតែក្រសួងមហាផ្ទៃក៏បានចេញបញ្ជាមិនឱ្យប្រើអំពើហិង្សាប្រឆាំងនិងបាតុករដោយសន្តិវិធីទេ ។ នរណាបញ្ជាឱ្យជួបរឿងនេះ គឺត្រូវជួបនឹងគ្រោះថ្នាក់ដ៏ធំមួយពីព្រោះពួកគេប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រី និងក្រសួងមហាផ្ទៃ"៕

## តមកទំព័រទី ៣ សម្ភាសន៍ជាមួយ សេរេណា ជួប...

ពាណិជ្ជកម្មមែន! តែពុំមែនសុទ្ធតែពាណិជ្ជកម្មទេ ពីព្រោះទីនេះនៅខ្វះអ្នកចេះដឹង ខ្លះមិនទាន់ចេះថែទាំមាត់ខ្លួនឯងនៅឡើយទេ ហើយឥឡូវគេអាចនិយាយសួរ ខ្ញុំដោយគ្មានទើសទាល់ខ្ញុំអាចនិយាយឆ្លើយជាភាសាខ្មែរយ៉ាងស្រួលយល់បង្កើនភាពងាយស្រួលចេះដឹងបានច្រើន។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** ហេតុអ្វីក៏បណ្ឌិត សេរេណា ជួប ជ្រើសផ្នែកមួយនៃខ្លួនមនុស្ស គឺមាត់ថា សំខាន់ជាងគេ?

**សេរេណា ជួប :** បើមនុស្សមិនមានសុខភាពល្អនៅមាត់ខ្លួននោះទេ គឺខ្លួនទាំងមូលនឹងគ្មានសុខភាពល្អ -អ្វីៗទាំងអស់ នៃមនុស្សវាតភ្ជាប់គ្នាទាំងអស់ -ការឈឺបេះដូងក៏មានបុព្វហេតុនៅក្នុងមាត់ដែរ...។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** តើសហគមន៍ខ្មែរ មានជម្ងឺក្នុងមាត់ច្រើនទេ?

**សេរេណា ជួប :** ខ្ញុំគួរនិយាយថា ខ្មែរយើងមិនសូវយល់ពីការថែទាំមាត់ឱ្យបានច្បាស់លាស់ទេ -ពួកបរទេសស្បែកសជាពិសេស មានការយល់ដឹងច្រើនពីការថែទាំមាត់របស់ខ្លួន -ចំណែកកូនខ្មែរជំនាន់ក្រោយមានការបង្ហាត់ហ្វឹកហ្វឺននៅសាលា ក៏ទទួលចំណេះដឹងច្រើនជាងមនុស្សជំនាន់មុនខ្លួន -ដូច្នេះថែទាំធ្មេញ -ការព្យាបាលមាត់ គឺការមិនរវល់នឹងមាត់ គឺពុំមានចំណេះខាងថែរក្សាមាត់ដោយពុំមាននរណារំលឹកពួកគាត់ ពីភាពចាំបាច់ទាំងនោះទេ។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** ពលរដ្ឋខ្វះចំណេះដឹង យើងអ្នកចេះស្រឡាញ់ពលរដ្ឋយើង តើយើងត្រូវធ្វើអ្វី?

**សេរេណា ជួប :** តាមរយៈលោកហ្នឹងឯង! ខ្ញុំសង្ឃឹមថា សាររបស់យើងនឹងបញ្ជូនតាមរយៈកាសែត ទៅប្រាប់បងប្អូន មិត្តភ័ក្រ្តថា ហេតុអ្វីបានជាមានសារប្រយោជន៍នឹងទៅឱ្យពេទ្យពិនិត្យអាការៈមាត់នឹងធ្មេញ គឺជាសុខភាពនៃរូបរាងកាយរបស់អ្នកនោះ។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** យើងប្រាកដជាត្រូវការសារពីគ្រូពេទ្យបញ្ជូនទៅឱ្យសាធារណជន ស្ដីអំពីជម្ងឺនានានោះហើយ -យើងនឹងស្វាគមន៍ជានិច្ចនូវរាល់សារទាំងនោះ នៅលើទំព័រសុខភាពរបស់ខ្មែរប៉ុស្តិ៍ស.រ.អា។

**សេរេណា ជួប :** ខ្ញុំបានធ្វើការណែនាំ អប់រំពីមាត់តាមរយៈភ្ញៀវ **តទៅទំព័រទី០៧**

និងមិត្តភ័ក្រ្តដែលមកទីនេះច្រើនណាស់ ហើយដែរ



តែខ្ញុំនៅតែជឿថា ការអប់រំតាមរយៈខ្មែរប៉ុស្តិ៍គឺតែប្រសើរ។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** យើងដឹងថា មន្ទីរពេទ្យធ្មេញនេះទទួលអ៊ិនស្វ៊ិនស្ទើរតែទាំងអស់ ចុះចំពោះអ្នកគ្មានអ៊ិនស្វ៊ិនវិញ មានវិធីជួយដែរឬទេ?

**សេរេណា ជួប :** ខ្ញុំមានការបញ្ចុះថ្លៃពិសេសដល់អ្នកដែលគ្មានអ៊ិនស្វ៊ិន -តែខ្ញុំសង្កេតឃើញថា មានបងប្អូនខ្លះមានអ៊ិនស្វ៊ិន រដ្ឋ Mass-Health ដែលគេចេញតម្លៃព្យាបាលឱ្យទាំងអស់ ក៏គាត់មិនបានមកឱ្យគេឆែកមើលមាត់ដែរ -គេគ្មានត្រូវការពីគាត់អ្វីក្រៅតែពីឱ្យគាត់មកព្យាបាលតែប៉ុណ្ណោះ។

**ខ្មែរប៉ុស្តិ៍ស.រ.អា :** យើងសូមអរគុណចំពោះការផ្ដល់បទសម្ភាសន៍នេះ ដោយសង្ឃឹមថា បណ្ឌិតទន្តសាស្ត្រ សេរេណា ជួប នឹងផ្ដល់អត្ថបទអប់រំសុខភាពបន្តបន្ទាប់គ្នាជាមិនខាន៕ **ដោយ : ពិន សំខុន**


# ពេទ្យធ្មេញសំរាប់គ្រួសារ Caring Dental For ALL Ages




COMPLETE ផ្ដល់គ្រប់សេវាកម្ម Services

- Cosmetic Dentistry
- Cosmetic Fillings
- Crowns & Bridges
- Dentures
- Extractions
- Implant Crowns
- Root Canal Therapy

- ត្រួតពិនិត្យទៀតទាត់ពេល
- សំអាតធ្មេញ
- ជំងឺចញ្ចៀមធ្មេញ
- ដកសរសៃធ្មេញ
- ស្រោប-តម្រឹម និងប៉ះធ្មេញ
- ធ្វើធ្មេញឱ្យស
- បំពេញធ្មេញប្រហោង
- ដកធ្មេញ

Most Forms of Insurance & Payment
ACCEPTED ទទួលគ្រប់ អ៊ិនស្វ៊ិន
MassHealth • Cigna • Aetna
Amex • Discover • Visa • Mastercard

Convenient LOCATION
Next to Bank of America on Chelmsford Street



FREE Teeth Whitening
New patients get a complimentary teeth whitening kit with completed exam, cleaning & x-rays at regular price. Cannot be combined with any other offers. Expires 30/04/2012

"EXCLUSIVE OFFER" $55.00 Limited Time New Patient Special
(Regular Discount $55.99 a $250 Value)
Present coupon for discount. Includes exam, bite-wing x-ray & cleaning. Cannot be combined with other offers or insurance. Expires 30/04/2012

យើងមានអ្នកនិយាយភាសាខ្មែរ អង់គ្លេស ស្ប៉ាញ៉ុល និងវៀតណាម សូមទូរស័ព្ទ 978-455-4039 ដើម្បីណាត់ជួបនៅថ្ងៃនេះ

724 Chelmsford Street • Lowell, MA • 978-455-4039
www.BrightSmiles–Dental.com


SIM'S
Major Sim Enterprises, Inc.
Home Improvement
ជាងសំណង់តាស៊ីម
License#CS 88569 Registration#153685
978-452-7467 / 978-421-3672 / 978-420-8551
FREE ESTIMATES
60 Middlesex St. (Rte.110) Lowell. MA 01852
FULLY INSURED
ជួសជុល កែលំអរ សង់បន្ថែម
Kitchen ចង្ក្រានបាយ
Livingroom បន្ទប់ទទួលភ្ញៀវ
Bathroom បន្ទប់ទឹក
Bedroom បន្ទប់ដេក
Roofing ដំបូល
Siding ជញ្ជាំង
Window បង្អួច
Door ទ្វារ
Basement ជាន់នៅក្រោមដី
Additions បន្ទប់បន្ថែម
Residential • Commercial • Industrial
ទទួលប្រាក់គ្រប់ប្រភេទ
Bank Loan, Insurance, Compensation, Credit Debit Card, Check &Cash
More information call: 1.978.452.7467
www.simshomeimprovement.com
Boreth@simshomeimprovement.com


ភោជនីយដ្ឋាន
ឆាយណាស្តារ
China Star
មានម្ហូបចិន
ម្ហូបប៉ូលីណេស៊ី
ម្ហូបចិនកង់តុង
ម្ហូបម៉ង់ដារិន
Chinese -Polynesian -Cantonese -Mandarin
369 Broadway St., Lowell, MA 01854
Tel: 978-454-7578, 978-454-7507
Open Daily: Sun. to Thurs. 11:00 AM to 1:00 AM
Fri. and Sat. 11:00 AM to 3:00 AM
យើងអាចយកម្ហូបទៅដល់ផ្ទះបាន
We Deliver All Day: 11:30 AM to
1:00 AM Available to most areas.
Min. $10.00 Delivery Charge $2
$16.95
បង្កងឆាខ្ញី និងខ្ទឹពិសេស
SPECIAL 2 Lobsters
w/ Scallion & Ginger


អាហារដ្ឋាន "បហ្វេ"
Mandarin Buffet
Parkway Plaza
1100 Revere Beach Parkway
Chelsea, MA 02150
617-889-0056
WWW.mandarinbuffetma.com
We have a full liquor license
China Buffet
Next to Target
203 Plain St.
Lowell, MA 01852
978-937-8868
WWW.chinabuffetma.com
Beer and Wine only
China Buffet
K-Mart Plaza180 Main
St.Saugus, MA 01906781-
231-1588
Beer and Wine only
Buffet includes American & Chinese food bar, Japanese sushi bar, BBQ & grill, fruits,salad bar, ice cream, dessert cakes and much much more!
10% OFF
Before meal Tax
W. Purchase over $10 or More for the next time visting
Cannot be combined w. any other offer!
For dining only. exclude holiday!
All valet in 3 location:
China Buffet in Lowell
Mandarin Buffet in Chelsea
China Buffet in Saugus
ALL YOU CAN EAT BUFFET... !!!

# សមាគមគាំទ្រគ្រួសារខ្មែរ

**ហ្វីឡាដែលហ្វៀ ៖** ប្រឈមមុខយ៉ាងអស់សង្ឃឹមតទល់នឹងភាពក្រីក្រភាពអវិជ្ជាគ្រួសារទ្រុឌទ្រោមគ្មានអនាគតគ្រួសារខ្មែរជាច្រើនបែរជាមានការខ្មាសអៀននឹងនិយាយប្រាប់ឱ្យគេឯងជួយ ឬក៏ខិតខំលាក់លាមសូកប៉ាន់មនុស្សខ្លះដែលពុំមានឯកទេសឱ្យជួយយ៉ាងស្ងៀមស្ងាត់ ។ លទ្ធផលនៃទង្វើនេះមិនបានដោះស្រាយបញ្ហាជីវិតយូរអង្វែងទេ ថែមទាំងប្រទាញមាត់ាជីវិតគ្រួសារឱ្យរីតតែលិចលង់ខ្លាំងឡើងទៅវិញ ។


Sosimon Chap, Elected CFSA Board President


Soben Pin, Secretary


Mao Man, Treasury



នាដើមខែមករានេះ មេគ្រួសារមួយក្រុមបានត្រៀមខ្លួនសម្រេចចិត្តផ្លាស់ប្តូរដំណោះស្រាយគ្រួសាររបៀបចាស់នេះចោលចេញ ដោយចងក្រងគ្នារៀបជាប្រព័ន្ធតាមបច្ចេកទេសវិទ្យាសាស្ត្រ ហើយចេញមុខមកដោះដូរយកយន្តការដែលនាំឱ្យគ្រួសារខ្មែរទ្រុឌទ្រោមនោះចោលចេញ ។ ក្រុមនោះនឹងបង្កើតសមាគមមួយមានឈ្មោះថា "សមាគមគាំទ្រគ្រួសារខ្មែរ" (Cambodian Family Services Association) មានទីតាំងបណ្តោះអាសន្ននៅវត្តព្រះពុទ្ធរង្សីហ្វីឡាដែលហ្វៀខាងត្បូង ។ គណៈកម្មាធិការមួយបានបង្កើតឡើង ហើយជ្រើសតាំងថ្នាក់ដឹកនាំមានប្រធានមួយរូប គឺអ្នកស្រី សូស៊ីមន ចាប លេខាធិការ គឺអ្នកស្រី សុបិន ពិន និងហិរញ្ញិក គឺលោក ម៉ៅ ម៉ន ។

ដើម្បីផ្តើមសកម្មភាពជួយដោះស្រាយបញ្ហាគ្រួសារក្នុងសហគមន៍ខ្មែរនេះ "សមាគមគាំទ្រគ្រួសារខ្មែរ" នឹងរៀបចំធ្វើបុណ្យផ្កាសាមគ្គីមួយយកបច្ច័យរៀបចំពង្រឹងសកម្មភាពរបស់ខ្លួននៅថ្ងៃទី២៤ មេសា ២០១២ នៅវត្តព្រះពុទ្ធរង្សី ។ មេរៀននៃអតីតកាលប្រាកដជានឹងធ្វើឱ្យពលរដ្ឋក្នុងសហគមន៍ដឹងការចង់ឱ្យមានការផ្លាស់ប្តូរទៅរករូបភាពគ្រួសារប្រសើរមានកូនចៅទៅរៀនបានចប់ចុងតាមបំណងប្រាថ្នា -ឪពុកម្តាយរស់នៅសុខដុមរមនាជាមួយកូន និងចៅ -ប្តីប្រពន្ធមានការពិគ្រោះក្នុងភាពស្មើគ្នានឹងក្នុងក្តីស្រឡាញ់ -ជីដូនជីតាមានការថែទាំសុខភាពទាំងកាយទាំងចិត្តឱ្យបានសមរម្យដូចការដែលយើងធ្លាប់គោរព... ។ល ។

គណកម្មការគ្រួសារខ្មែរនោះមានជំនឿយ៉ាងមុតមាំថា "រួមគ្នាជាធ្លុងមួយយើងប្រាកដជាលើករនាំងបាំងអភិវឌ្ឍនោះចេញបាន ដើម្បីអនាគតគ្រួសារកូនចៅខ្មែរយើងត្រូវតែមូរដៃអាវធ្វើការឱ្យចំទិសដៅពីពេលនេះទៅកុំរង់ចាំអីតទៅទៀត" ។

គណកម្មការបុណ្យផ្កាសាមគ្គីនឹងមានសេចក្តីរីករាយឆ្លើយសំណួរលោកអ្នក អ្នកស្រី សូស៊ីមន ចាប លេខ **២១៥-៤៥៥-៧៥៥៦** លោក ឈឿន ផល លេខ **២១៥-៤៣៥-៩៧៣៣** លោក ត្រៃ ហ៊ល លេខ **២១៥-២៥៤-៩៦៨២** លោក វ៉ាន់ថន ទូច លេខ **២៦៧-៥៣៩-៦៧១៦** លោក ម៉ៅ ម៉ន លេខ **២៦៧-៣២០-៧៤៦៩** លោក ពិន សំខុន លេខ **២១៥-៩១៣-០០៨៣** លោក ហ៊ូ តេង លេខ **២៦៧-២៤៣-៧៧១០** អ្នកស្រី សុបិន ពិន លេខ **២៦៧-២៥៣-៣៩៤៧** លោក ម៉ម យីន លេខ **២១៥-៤៥៧-៣៦៨៤** លោក គិម ភៀន លេខ **២១៥-៦៨០-២០៥៩** ៕

**ដោយ ៖ ខ្មែរប៉ុស្តិ៍**




## Gov´t Objects to Thai Pagoda...

Continue From pag 06

[Wednesday] and the note was copied to the ICJ, too," he said in a brief email.

Lieutenant General Srey Dek, commander of RCAF´s 3rd Division and provisional commander of forces at Preah Vihear, confirmed the report of Thailand´s attempt to move construction material and a Buddha statue up the hill but referred all other questions to deputy provincial governor Sar Thavy, who could not be reached.

None of the Cambodian officials specified precisely which clause of the ICJ´s July 18 ruling Thailand had violated.

Besides ordering Thai and Cambodian troops out of the demilitarized zone, it calls on both sides to "refrain from any action which might aggravate or extend the dispute before the court or make it more difficult to resolve."

Thai Ambassador Sompong Sanguanbun said he was in Bangkok and was unaware of the situation. A spokesman for the Thai army declined to comment.

Thailand and Cambodian appeared to have reached a modest breakthrough in December when their defense ministers, at a long awaited meeting in Phnom Penh, agreed to form a joint working group to hash out the final details of the ICJ-ordered withdrawal. That working group has yet to meet, however, and Cambodia says it is only waiting on an invitation from Thailand for those talks to start.

33rd Annual
Cambodian New Year
CELEBRATION
Cultural Performances | Sit-Down Dinner | Social Dancing | Live Band

33rd Annual
Cambodian New Year
អបអរសាទរបុណ្យចូលឆ្នាំថ្មី
មានសិល្បៈខ្មែរ - អាហារពេលល្ងាច - រាំកំសាន្តជាមួយតន្ត្រីសម័យ



HILTON HOTEL
SAT, APRIL 7th, 2012
6:00PM to 12:00AM
4200 City Avenue
Philadelphia, PA 19131
Formal Attire

ADVANCE TICKETS $55 | AFTER MARCH 15th $65
RSVP Contact: Cindy Suy cagpevent@gmail.com | 215-971-5785 | www.cagp.org
PROCEEDS BENEFIT INTER-GENERATIONAL PROGRAMS

CAMBODIAN ASSOCIATION OF GREATER PHILADELPHIA, INC.
www.cagp.org | facebook.com/cagpevents | twitter.com/cagpevents

HILTON HOTEL
4200 City Avenue, Philadelphia, PA 19131
ថ្ងៃសៅរ៍ ទី៧ ខែមេសា ឆ្នាំ ២០១២
ពីម៉ោង៦ល្ងាច ដល់ម៉ោង១២អធ្រាត្រ
សំលៀកបំពាក់សមរម្យ

សំបុត្រមួយតំលៃ៥៥ដុល្លា ក្រោយថ្ងៃទី១៥ ខែមីនា តំលៃ៦៥ដុល្លា
សូមទូរស័ព្ទមកលេខ ២១៥-៣២៥-៥០៧០ ឬ ២១៥-៩៧១-៥៧៨៥។
ប្រាក់ចំណូលនឹងយកមកផ្គត់ផ្គង់កម្មវិធីទូរទៅរបស់សមាគមខ្មែរ

សមាគមខ្មែរនៅតំបន់ហ្វីឡាដែលហ្វៀ
CAMBODIAN ASSOCIATION OF GREATER PHILADELPHIA, INC.
www.cagp.org | facebook.com/cagpevents | twitter.com/cagpevents

Vihi insurance-Income Tax Mortgage-Realty
ធានារ៉ាប់រង_តាក់លើប្រាក់ចំណូល_ខ្ចីប្រាក់ទិញផ្ទះ_ទិញលក់ផ្ទះ

Insurance ធានារ៉ាប់រង
(Licensed PA, NJ & DE) អាជ្ញាប័ណ្ណ PA, NJ & DE
Home • ផ្ទះ Car • រថយន្ត
Business • មុខរបរ Health • សុខភាព
Income Tax តាក់លើប្រាក់ចំណូល
Individual • ផ្ទាល់ខ្លួន Business • ពីមុខរបរ
Pay Roll • ពីប្រាក់ខែ
Forming New Business • បង្កើតមុខជំនួញថ្មី
Home Deed Transfer • ប្តូរឈ្មោះផ្ទះ
Auto Title Transfer • ប្តូរឈ្មោះម្ចាស់រថយន្ត




Vihi Mortgage Vihi ខ្ចីប្រាក់ទិញផ្ទះ
(Licensed by PA Dept. of Banking) • អាជ្ញាប័ណ្ណពី PA ការិយាល័យធានាគារ
Hiep Vo, MBA, President. • ហ៊ីប វ៉ូ MBA ប្រធាន
Finance/Refinance your home • ផ្តល់ប្រាក់កម្ចីក្នុងការទិញផ្ទះទិញដំបូង ឬកណ្តាលទី
Low interest Rate & Down Payment • ការប្រាក់ថោក និងលុយកក់តិច
Fast Preapproval • ចម្លើយលឿន

Vihi Realty Co
Dr. Hanh Vo, Broker/Owner Cell (267) 664-2689
Buy & Sell Properties & Businesses
Visit: www.drhanh.net for more foreclosure homes

North Phila – 215-276-8441
5225 N. 5th Street
Phila., Pa 19120

South Phila – 215-336-0600
1519 W. Passyunk Ave.
Phila., Pa 19145
www.vihifinancial.com

Yoo's Auto Service and Collision
យូ បំរើសេវារថយន្ត
នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច



FREE ESTIMATES
យើងអាចជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។

រោងជាងម៉ាស៊ីន
Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission
Inspection & Repairs
Muffler & More

រោងជួសជុលតួរថយន្ត
Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists




189 W. Duncannon Ave. Phila., PA 19120
ទូរស័ព្ទ SAM 215-457-7777 ឬ
215-457-7779, Fax-215-457-7475


SAVE THE DATE
2nd ANNUAL LOWELL SOUTHEAST ASIAN WATER FESTIVAL FUNDRAISING EVENT
CELEBRATING 16 YEARS OF CULTURE AND TRADITION
LOWELL SOUTHEAST ASIAN WATER FESTIVAL
SATURDAY March 24, 2012
SAMPAO MEAS RESTAURANT
450 Chelmsford St. Lowell, MA
7:00pm-12:00am
$30 IN ADVANCE/ $35 AT THE DOOR
INCLUDES: 3 COURSE MEAL, COCKTAIL HOURS 7PM-8PM
FEATURING: BAD BOYZ BAND
SOUTHEAST DANCE PERFORMANCES
FOR MORE INFORMATION ON TICKETS AND SPONSORSHIP
CONTACT: MOLYMTM@YAHOO.COM
WEBSITE: HTTP://LOWELLWATERFESTIVAL.COM
FACEBOOK: LOWELL SOUTHEAST ASIAN WATER FESTIVAL


ហាងមាសរស្មី
SUNSHINE JEWELRY, INC.
215-271-2950
Certified Diamonds & Golds (24K & 18K)
Men & Women Jewelries & Watches
Custom Design & Repairs on Premise
15 Years in Services & Growing Strong
SUNSHINE
702 Washington Ave. Phila., PA 19147
www.sunshinejewelryonline.com


ហាងមាសខ្មែរអង្គរ
Khmer-Angkor
金美成珠寶行 Jewelry
Since 1983
Certified Diamonds & Diamond Jewelry
18K & 24K Gold, Platinum Jewelry & Watches
GIA Graduate Gemologist on Staff
Authorized RADO & LONGINES Dealer
Repairs Done on Premises
600 Washington Avenue. Unit 12B.
Philadelphia, PA 19147
Tel. 215-599-2222
Fax. 215-599-2223
Open
Tuesday-Sunday
10:30AM-6:30PM
Closed Monday
Photo by Kay Lim Photography

# បើកកម្មវិធីដេញថ្លៃឡានជាសាធារណៈ:

300+ Cars a week

**INTERSTATE Auto Auction** Auctioncar.net (603) 893-7777

**In Salem, NH-Just 20 Minutes from Lowell MA**

# OPEN TO THE PUBLIC LIVE CAR AUCTION

## Saturdays 10:30AM

***Test Starts/Preview! Starts at 9AM***

## Wednesdays 5:30PM

***Free Test Drives Before You Buy!***

**Starts Wednesday at 9AM-5PM**

Only 40 Minutes From Lynn and Revere, MA
Just Over 1 Hour from Providence, RI
Or You Can Even Bid Online From Philadelphia, PA or New Jersey and Have The Car Delivered to Your Home"

**www.interstateautoauction.com**

**NH Lic#Auctioneer Alan Chambers/20 Hampshire Road - Salem NH 03079**










-ឥតមានកក់លុយ សម្រាប់ដេញថ្លៃនៅក្នុង Online ឬទៅកន្លែងទេ -មានឡាន៣០០ ក្នុងមួយសប្តាហ៍
-Inter State Auto Auction, Salem NH ដែលនៅចម្ងាយ២០នាទីពីក្រុងឡូវែល អ្នកណាក៏អាចចូលរួមបានដែរ !
-**នៅថ្ងៃសៅរ៍ ម៉ោង១០:០០ព្រឹក** លោកអ្នកអាចបញ្ចេះឡាន/ការសម្តែងឡានមុនម៉ោង៩ព្រឹក
-**ថ្ងៃពុធនៅវេលាម៉ោង៥:៣០នាទីល្ងាច** : លោកអ្នកអាចបើកឡានសាកល្បងពីរម៉ោង៩ព្រឹកដល់ម៉ោង៥ល្ងាច

# ជោគជតារាសីទាំង 12 ប្រចាំឆ្នាំរោង

ជោគជតាប្រចាំសប្តាហ៍

**ឆ្នាំជូត**

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរ បានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះ អ្វីៗច្រើនមានការប្រែប្រួលពុំទៀងទាត់ឡើយ ដូច្នេះបើលោកអ្នកមានលក់ដីធ្លី ផ្ទះសម្បែង ឬវត្ថុមានតម្លៃផ្សេងៗ ចូរធ្វើលិខិតស្នាមជាលាយល័ក្ខអក្សរដោយមានចុះហត្ថលេខា ឬផ្តិតស្នាមមេដៃឱ្យបានត្រឹមត្រូវ ទើបទៅថ្ងៃមុខពុំមានបញ្ហាចោទឡើង ។ ចំពោះគូស្នេហ៍មានភាពស្និទ្ធស្នាលដូចប្រក្រតី ៕

**ឆ្នាំឆ្លូវ**

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះអ្វីៗច្រើន មានការប្រែប្រួលពុំទៀងទាត់ឡើយ ។ ដូច្នេះបើលោកអ្នកមានទិញលក់ដីធ្លីផ្ទះ ឬវត្ថុមានតម្លៃផ្សេងៗ ចូរធ្វើលិខិតស្នាមដោយមានចុះហត្ថលេខា ឬផ្តិតស្នាមមេដៃឱ្យបានត្រឹមត្រូវ ទើបទៅពុំ មានបញ្ហាចោទឡើង ។ ចំពោះគូស្នេហ៍ប្រកបតែសេចក្តីសុខ ក្សេមក្សាន្ត ៕

**ឆ្នាំខាល**

រាសីលោកអ្នកល្អមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែលោកអ្នកអាចរកផលចំណូលបានច្រើនគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ បើស្រលាញ់កុំទៅញីកបើរលឹកកុំទៅញយ ទើបចំណងស្នេហ៍អាចគង់វង្សបានយូរអង្វែង ៕

**ឆ្នាំថោះ**

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើន លូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ លោកអ្នកមានអារម្មណ៍ភ្លឺថ្លាត់និតប្រាជ្ញាឈ្លាសវៃ បើបានជួបពិគ្រោះពិភាក្សាការងាររកស៊ីនឹងឆាប់និយាយត្រូវរ៉ូវ និងមានការចុះសម្រុងនឹងគ្នា ។ ចំពោះអាជីវករនឹងមានទំនិញលក់ចេញទិញចូល ឥតទំនេរដៃព្រមទាំងមានភោគផលកម្រៃហូរចូលច្រើនទៀតផង ៕

**ឆ្នាំរោង**

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងឈ្លោះវិវាទកើតឡើង ចូរចេះអត់ធ្មត់និងរំងាប់ចិត្តឱ្យបានត្រជាក់ ។ ចំពោះស្ត្រីភេទក្នុងរយៈពេលនេះ មិនត្រូវនិយាយស្តីប៉ប៉ាច់ប៉ប៉ោចឥតបានការច្រើនពេកទេ ព្រោះរឿងរ៉ាវផ្សេងៗ អាចកើតចេញពី ពាក្យសម្តី ។ ចំពោះគូស្វាមីភរិយា ចូរប្រយ័ត្នប្រយែងក្រែងមានអ្នកទីបីចូលជ្រៀតជ្រែកនៅក្នុងគ្រួសារ ៕

**ឆ្នាំម្សាញ់**

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ក៏ត្រូវបានបងប្អូនញាតិមិត្តជួយជ្រោមជ្រែងយ៉ាងពេញទំហឹងដែរ ដូច្នេះចូរញាប់ដៃញាប់ជើងបន្តិច ព្រោះការងារជាមាសប្រាក់ធ្វើច្រើនបានច្រើន ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះស្គាល់តែភាព ផ្អែមល្ហែមដូចទឹកឃ្មុំ ៕

**ឆ្នាំមមី**

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ លោកអ្នកមានអារម្មណ៍ភ្លឺថ្លាត់និតប្រាជ្ញាឈ្លាសវៃ ទោះបានប្រកបកិច្ចការងារអ្វីៗក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ តែចូរកុំមានចិត្តលោភលន់ឱ្យសោះ ព្រោះការលោភលន់នាំមកនូវក្តីវិនាសអន្តរាយ ។ ចំពោះគូស្នេហ៍មានភាពល្អូកល្អឺន យល់ចិត្តគ្នាល្អណាស់ ៕

**ឆ្នាំមមែ**

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបបញ្ហាលំបាកៗច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ចូរមានការប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសចំពោះអ្នកជំនួញជួញដូរមុននឹងប្រគល់ ឬទទួលនូវមុខទំនិញសព្វសារពើត្រូវចេះពិនិត្យមើលគុណភាព និងរាប់ចំនួន ឱ្យបានត្រឹមត្រូវទើបមិនចាញ់បោកគេ ។ ចំពោះគូស្នេហ៍ក្នុងរយៈ ពេលនេះច្រើនពាក់មុខយក្សដាក់គ្នា ៕

**ឆ្នាំវក**

រាសីលោកអ្នកល្អមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ បើមានបងប្អូនញាតិមិត្តស្កាត់មកបបួលរកស៊ីចូលហ៊ុនជាមួយ តោងចេះត្រិះរិះពិចារណាឱ្យបានល្អិតល្អន់ទើបមិនចាញ់បោកគេ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ ប្រសិនបើបានស្គាល់ចិត្តថ្លើមគ្នាហើយ គឺអាចគិតគូររឿងអាពាហ៍ពិពាហ៍បាន ៕

**ឆ្នាំរកា**

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ គឺរមែងតែងតែបានទទួលផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ ក្នុងរយៈពេលនេះបុរសត្រូវប្រយ័ត្នចំពោះ មនុស្សស្រីដែលមានសម្តីផ្អែមត្រជាក់អាចរលាយទ្រព្យឆាប់ ។ ចំពោះគូស្នេហ៍ប្រកបតែសេចក្តីសុខក្សេមក្សាន្ត ៕

**ឆ្នាំច**

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរ មានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះដោយទំនាយទាយថា អាចបង់ខាតទ្រព្យខ្លះៗនោះ ដូច្នេះចូរកុំឱ្យគេខ្ចីរបស់របរមានតម្លៃឱ្យសោះ ព្រោះកាលបើបានធ្លាក់ដល់ដៃគេហើយ គឺគ្មានថ្ងៃបានវិលត្រឡប់វិញឡើយ ។ ចំពោះគូស្វាមីភរិយាក្នុងរយៈពេលនេះ មានផលប៉ះទង្គិចគ្នាបន្តិចបន្តួច ៕

**ឆ្នាំកុរ**

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែមានភោគផលចំណូលហូរចូលច្រើនគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ហើយក៏មិនខុសពីទូកធំក្តោងធំនោះដែរ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ ទាល់តែចេះអត់ឱនឱ្យគ្នាទៅវិញទៅមកទើបមិនអាចប្រេះឆាគ្នាបាន ៕




# ANGKOR AUTO SERVICE, INC.

## ហាងជួសជុលរថយន្ត "អង្គរ"

**Free Estimate**

**Auto Body and Maintenance**



BODY WORKS

Auto glass and windshields

Auto Frame Straightening and Painting

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វ៊ីរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES

State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

# ភោជនីយដ្ឋាន ណាម វាង (ភ្នំពេញ)

## Nam Vang Restaurant

**571 Unit#1 Adams Svenue. Philadelphia, PA 19120**
**(inside Hong Kong Market) (215) 742-9488**





រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់ប្រភេទផ្លែឈើ ដូចជា: ធុរេន ឬ អាវូកាដូ ហើយជាពិសេស មានទឹកអំពៅស្រស់ៗ



១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា :
-គុយទាវភ្នំពេញ
-គុយទាវ ឬមី-ខគោ
-មីកន្ថាំង ឆាសាច់គោ
-មីកន្ថាំងឆាគ្រឿងសមុទ្រ
-បាយឆាគ្រប់មុខ
-សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

២_មុខជំនាញម្ហូបវៀតណាម ឈ្ងុយឆ្ងាញ់ ដូចជា :
-នំបញ្ចុកទឹកត្រីពិសេស
-នំបុ័ងបាតេ ឬសាច់គោអាំង
-ខគោ នំបុ័ង ឬ មី និងគុយទាវ
-បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

**Open 7 days a week from 9a.m-9p.m**
**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ អង្គរ

# ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ-អង្គរ

(Since 1991)

## Angkor International Travel Agency





World Wide Travel & Tour Service
Cambodia - Vietnam - Laos - Thailand

ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ សេវាអន្តោប្រវេសន៍
សេវាលិខិតឆ្លងដែន កក់សណ្ឋាគារ ឬជួលឡាន

**USA**
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com

**Cambodia Office: Victory Travel (Skin Belle)**
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.

SERVING SINGAPOR, EVA AIR, CHINA, ASIANA KOREAN AILINES



# ហាងខ្មែរជួសជុលរថយន្ត

**បើចង់ឱ្យរថយន្តលោកអ្នកកែបានល្អ សូមអញ្ជើញ**

# Rathe's Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកិរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376




ជាហាងដែលធ្វើ ហ្វើ ឆ្ងាញ់ជាងគេនៅហ្វីឡាដែលហ្វៀ
ចុងភៅដែលពូកែធ្វើ ហ្វើ និងម្ហូបផ្សេងៗឯទៀត
ត្រូវមាត់ភ្ញៀវគ្រប់ៗរូប ឥឡូវនេះមកធ្វើម្ហូបនៅហាងយើងខ្ញុំ
ហើយធានាថា ម្ហូបអាហារហាង Phở Hà Saigon
និងបំរើលោកអ្នកបានយ៉ាងពេញចិត្តគ្រប់ពេលវេលា




320 W. Oregon Avenue, Suite 1. Philadelphia, PA 19147
Tel: (215) 389-1002 (Inside Oregon Market)

VISA MasterCard DISCOVER

ភោជនីយដ្ឋានកូរ៉េ
សេអូរ៉េបូល
SEORABOL
Sushi & sasimi
KOREAN * JAPANESE RESTAURANT
(Mon,- Satr: Ham to 11pm)(Sunsay: 11am to 10 pm) www.seorabolphilly.com

BBQ HOUSE
서라벌회관
(215) 924-3355
5734 Older 2nd St
Phila, PA 191 20

ភោជនីយដ្ឋានកូរ៉េដ៏ល្បីឈ្មោះនៅហ្វីឡាដែលហ្វៀ





- មានសាច់អាំង "បាបេគ្យូ" របៀបកូរ៉េ
- មានម្ហូបជប៉ុនគ្រប់យ៉ាង-ស៊ូស៊ី ។ល។
- មានភេសជ្ជៈ "ស្រាវ៉ាញកូរ៉េ" ផ្អែមហើយឆ្ងាញ់គ្រប់ប្រភេទ
- មានបន្ទប់ "ភ្ញៀវកិត្តិយស VIP" បរិយាកាសយ៉ាងប្រសើរ សម្រាប់ភ្ញៀវពី១០ទៅ ៤០នាក់
- មានកន្លែងចតរថយន្តធំទូលាយ


ម្ហូបខ្មែរទាន់ចិត្ត
Kavei
ប្រហុកកប់ផ្សិតក្តួនត្រី
KAVEI Xpress
AUTHENTIC CAMBODIAN CUISINE
2223-25 S 7TH STREET, PHILADELPHIA, PA 19148
EAT IN - TAKE OUT
215.755.2151
OPEN 6 DAYS A WEEK
10am-8pm